# ពលរដ្ឋរងគ្រោះពីការលុបបឹងតាមោកស្នើដល់តុលាការឱ្យទម្លាក់បទចោទប្រកាន់។



ពលរដ្ឋរងគ្រោះដោយជម្លោះដី នៅបឹងតាមោក ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ចូលរួមតវ៉ានាពេលកន្លងទៅ។

ពលរដ្ឋរងគ្រោះពីការលុបបឹងតាមោកស្នើដល់តុលាការទម្លាក់បទចោទប្រកាន់លើពួកគាត់ ។ សង្គមស៊ីវិលស្នើឲ្យតុលាការស៊ើបអង្កេតឲ្យបានច្បាស់លាស់ និងកុំលម្អៀងទៅរកភាគីមានអំណាចណាមួយដើម្បីផ្ដល់យុត្តិធម៌ពិតជូនពលរដ្ឋរងគ្រោះ និងបញ្ឈប់អំពើនិទ្ទណ្ឌភាព។

ពលរដ្ឋរងគ្រោះពីការលុបបឹងតាមោកព្រួយបារម្ភអំពីសុវត្ថិភាព ខណៈឃើញដីកាបង្គាប់ឲ្យចូលខ្លួននៅថ្ងៃទី២១ ខែកុម្ភៈ ខាងមុខនេះ។

លោកស្រី គង់ តឿ ប្រាប់វិទ្យុអាស៊ីសេរី ថា លោកស្រីពិតជាព្រួយបារម្ភមិនដឹងថា រឿងនេះនឹងទៅជាយ៉ាងណានោះទេ។ លោកស្រីយល់ឃើញថា ការចោទប្រកាន់ពួកលោកស្រីដែលជាអ្នកភូមិរស់នៅបឹងតាមោកថា ប្រើហិង្សាប្រឆាំងនឹងរាជការសាធារណៈ ជាបទល្មើសដ៏ធ្ងន់ធ្ងរ។ លោកស្រីស្នើដល់តុលាការឲ្យទម្លាក់បទចោទទាំងនេះលើពលរដ្ឋរងគ្រោះទាំង៩នាក់។

លោកស្រី គង់ តឿ៖ «*ខ្ញុំសុំឲ្យអាជ្ញាធរកុំឲ្យធ្វើបាប លើកបទចោទទៅកុំឲ្យធ្វើបុកទុក្ខម្នេញប្រជាពលរដ្ឋអ៊ីចឹងហើយបើដីហ្នឹង បើចង់បានដោះស្រាយឲ្យប្រជាពលរដ្ឋមកតាមតម្លៃទីផ្សារចុះ ខ្ញុំសូមឲ្យសម្ដេចជួយប្រជាជនផងព្រោះប្រជាជនសុំតែថា ២៥០ គ្រួសារហ្នឹងមានដីតែ៥ហិកតាទេ ហេតុអ៊ីគេនៅបុរីប៉ុនចេស សាងសង់បានទើបក្រោយខ្ញុំផង ២០១៥ទេ ហើយគេរស់នៅបាន ហើយខ្ញុំជាប្រជាពលរដ្ឋ គេមានប្លង់កម្មសិទ្ធិសងខាង ខ្ញុំនៅកណ្ដាលអត់មានប្លង់កម្មសិទ្ធិទេ សូមឲ្យសម្ដេចជួយ*»។

ការព្រួយបារម្ភរបស់លោកស្រី គង់ តឿ នេះ ធ្វើឡើងបន្ទាប់ពីសាលាដំបូងរាជធានីភ្នំពេញ ចេញដីកាបង្គាប់ឲ្យលោកស្រី ចូលខ្លួនដើម្បីសារសួរពាក់ព័ន្ធនឹងសំណុំរឿងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងរាជការសាធារណៈប្រព្រឹត្តទៅនៅសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ តុលា ឆ្នាំ២០២២កន្លងទៅ។ ដីកាបង្គាប់ឲ្យចូលខ្លួននេះ តម្រូវឱ្យអ្នកភូមិពីរនាក់ក្នុងចំណោម ៩នាក់ដែលត្រូវចោទ គឺលោកស្រី គង់ តឿ និង លោកស្រី តាន់ ខ្មី ចូលទៅបំភ្លឺតុលាការ។

លោកស្រី គង់ តឿ បញ្ជាក់ថា គាត់នឹងមិនចូលខ្លួនតាមដីកាកោះហៅនេះទេ ព្រោះមេធាវីរបស់លោកស្រីជាប់រវល់ ហើយមេធាវីសុំពន្យាពេលចូលខ្លួនទៅផ្ដល់ចម្លើយនៅពេលក្រោយ។

ពាក់ព័ន្ធនឹងករណីនេះ អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណ សុផាត មានប្រសាសន៍ថា លោកសង្កេតឃើញថា នៅពេលមានជម្លោះរវាងភាគីអាជ្ញាធរអនុវត្តច្បាប់ជាមួយពលរដ្ឋ មានតែភាគីពលរដ្ឋរងគ្រោះទេ ដែលត្រូវបានរងពាក្យបណ្តឹងផ្សេងៗពីតុលាការ ហើយភាគីអាជ្ញាធរដែលប្រើអំពើហិង្សាលើពលរដ្ឋវិញ មិនដែលឃើញរងទោសទណ្ឌណាមួយទេ។ លោកថា ទាំងនេះជាអំពើនិទ្ទណ្ឌភាពរបស់មន្ត្រីអនុវត្តច្បាប់ ដែលកាន់តែធ្ងន់ធ្ងរទៅៗទៅលើពលរដ្ឋ។

លោក វណ្ណ សុផាត៖ *«ខ្ញុំសំណូមពរឲ្យរដ្ឋធ្វើម៉េចអនុវត្តទៅតាមនីតិវិធីទី១ ហើយទី២ សូមឲ្យខាងតុលាការហ្នឹង គាត់ធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ កុំឲ្យមានល្អៀងទៅលើអ្នកមានអំណាច ឬមួយក៏ក្រុមហ៊ុន ឬក៏ភាគីម្ខាងទៀតដែលមានសមត្ថភាព មានលទ្ធភាពជាងប្រជាពលរដ្ឋហ្នឹងហាំ គួរតែគិតពីសមធម៌សង្គមផងបាទ កុំឲ្យតែគាត់ផ្អែកតែទៅលើ ប្រយោជន៍ ឬមួយក៏ការរាយការណ៍ពីថ្នាក់ក្រោម ព្រោះរឿងខ្លះហ្នឹង ថ្នាក់ក្រោមហ្នឹង សុទ្ធតែជាការដាក់ភស្តុតាងដាក់ទម្ងន់បន្ថែម ដាក់បន្ទុកបន្ថែមទៅលើប្រជាពលរដ្ឋ អ៊ីចឹងគួរតែតុលាការមានការស៊ើបអង្កេតឲ្យបានច្បាស់លាស់ឲ្យមានតម្លាភាពសម្រាប់ផ្តល់យុត្តិធម៌ជូនពលរដ្ឋផងហាំបាទ»*។

ពលរដ្ឋរងគ្រោះរៀបរាប់ពីដំណើរដើមទងនៃទំនាស់ថា កាលល្ងាចថ្ងៃទី០១ តុលា ឆ្នាំ២០២២ ថា ដំបូងឡើយពលរដ្ឋនៅបឹងតាមោក បានទៅសាលាខណ្ឌ ស្នើជួសជុលផ្ទះសម្បែងរបស់ពួកគាត់។ ពេលត្រឡប់មកវិញ សាលាខណ្ឌបានឲ្យជាអង្ករ ទឹកត្រី និងសម្ភារៈមួយចំនួនមកជាមួយ។ ពេលដែលពលរដ្ឋនាំគ្នាធ្វើការជួសជុលទ្វាផ្ទះពួកគេ ស្រាប់តែអាជ្ញាធរមូលដ្ឋានហាមឃាត់មិនឲ្យពួកគាត់ធ្វើទេ។ បន្ទាប់មក ខាងអាជ្ញាធរក៏បានកាត់ខ្សែចងទ្វារបណ្ដាលឲ្យធ្លាក់ទ្វារចុះមកក្រោមនាំឲ្យបាក់

ទ្វារផ្ទះនោះទៅ ។ ភ្លាមនោះពលរដ្ឋក៏ខឹងសម្បារ ហើយនាំគ្នាយកអំណោយទាំងនោះដុតចោលតែម្តងទៅ ។ ពេលឃើញពលរដ្ឋដុតអំណោយចោលបែបនោះ អាជ្ញាធរបានស្ទុះមកទាត់ភ្នក់ភ្លើងនោះទៅលើពលរដ្ឋ ហើយទំនាស់កើតឡើងនៅពេលនោះមក៕